# វិធី តំលើង/ប្រើប្រាស់ កម្មវិធី FormatFactory ជា អក្សរខ្មែរ ១០០%

# សំរាប់បំលែង រំកើយឥតគតថ្លៃ ទ្រង់ទ្រាយ របស់ រូបភាព / អឌាវ / វិឌីអូ

ជាកូនខ្មែរ, បើអ្នក មិនប្រើប្រាស់ អក្សរខ្មែរ
**វិធីតំលើង ក្រមអក្សរខ្មែរយូនីកូដ-នីដា**
គ្មានបរទេសណា អភិវឌ្ឍវា ជំនួសអ្នក ទេ!

ខែ មេសា ៦, ២០១០ - ឈរ រ៉ាណ

ដូចដឹងស្រាប់, ពត៌មាន បច្ចុប្បន្ន លែងមាន និយមន័យចង្អៀត ដូចកាល កន្លះសតវត្ស កន្លង ដែលសង្កត់ន័យ សំដៅត្រឹម អក្សរលើកាសែតជាក្រដាស, សំលេង លើវិទ្យុ/ខ្សែអាត់, ជំនួនដំណឹង តាមឧបករបំពងសំលេង, រូបភាពលើក្រដាស, ...និងលែងត្រឹម អង្គការនានា, ពួករដ្ឋអំណាច, ពួកសហាគម ឬ ពួកក្រុមហ៊ុន អាចផលិត/ផ្សព្វផ្សាយ រាល់ពត៌មាន សូម្បី មហាជនរាល់រូប ឬ រាល់ប្រជាពលរដ្ឋសាមញ្ញ ក៏អាចផលិត/ផ្សព្វផ្សាយ តាមប៉ង រាល់ពត៌មាន និង ករណីខ្លះ ភាគច្រើន នៃពត៌មាន របស់មហាជនទាំងនោះ មាន ក៏រិតច្បាស់/ត្រឹមត្រូវ ខ្ពស់ជាង របស់ពួករដ្ឋអំណាច។




ពត៌មាន បច្ចុប្បន្ន សំបូរបែបពេក រហូតលែងត្រឹមជា អក្សរសាមញ្ញ លើក្រដាស, សំលេង សាមញ្ញ, ជំនួនដំណឹងសាមញ្ញ ប៉ុន្តែជា **មីឌា** (Media) ឬ **ពហុមីឌា** (Multimedia) សំរាប់បំពេញ ន័យ របស់ពត៌មាន នៃសតវត្ស ២១ ជាសតវត្ស នៃបច្ចេកវិទ្យា និងល្បឿនរន្ទះ របស់ពត៌មាន។

មីឌា ឬពហុមីឌា ជាពាក្យចំន័យ សំរាប់ពត៌មានបច្ចុប្បន្ន, វាមានលក្ខណៈ ជាអត្ថបទអក្សរសុទ្ធ (Text), ជារូបភាព (Pictures), ជាអឌាវ (Audio), ជាវិឌីអូ (Video), ឬ ជួនទាំងពីរទាំងបី ទាំងបួន រួមគ្នា។ ពួកវា សុទ្ធជា ប្រភេទទិន្នន័យលេខ (digital data) ក្រោមរូបភាព ជាសំណុំពត៌មាន (files)។

ពួកវា មានរាប់សិបទ្រង់ទ្រាយទីទៃ ត្រូវបានប្រទៈ លើទីផ្សារបច្ចុប្បន្ន ជាទូទៅ .jpeg .png .mp3 .wav .avi .flv ... អាស្រ័យ រោងផលិត (manufacturer) នីមួយ លេចធ្លោលើទីផ្សារ មាន Sony, Samsung, Toshiba, LG, Apple, ...

> មីឌា = អត្ថបទសុទ្ធ (text) ឬ រូបភាព (Pictures) ឬ អឌាវ (Audio) ឬ វិឌីអូ (video) ឬ ទាំងពីរទាំងបីទាំងបួនចូលគ្នា
>
> វិឌីអូ = អឌាវ (Audio) + រូបភាពកំរើក (motion picture)
>
> អឌាវ = អត្ថបទសុទ្ធ (Text) + សំលេង (Sound) + តន្ត្រី (Music)
>
> (អឌាវ អាចផងដែរ ជា ចំរៀងលេខ (Digital song))

វិឌីអូ ជា ប្រភេទពត៌មាន មានផ្ទុក អឌាវ និង រូបភាពកំរើក
អឌាវ ក៏ជា ប្រភេទពត៌មាន ប៉ុន្តែផ្ទុក អក្សរ, សំលេង, និង តន្ត្រី

ថ្វីបើ មីឌា មានច្រើនទ្រង់ទ្រាយទីទៃ ប៉ុន្តែ ក៏មានចឹងដែរ វិធីដោះស្រាយ សំរាប់ប្រើប្រាស់ពួកវា។ កម្មវិធី FormatFactory ជា មួយនៃពពួកកម្មវិធី សំរាប់បំលែង គ្រប់ប្រភេទទ្រង់ទ្រាយ របស់មីឌា ទៅទ្រង់ទ្រាយ ត្រូវតាមឧបករ (ទូរសព្ទចល័ត, សំភារៈចល័ត, ឧបករថតរូប, ឧបករថតវិឌីអូ ) អ្នកកំពុងប្រើប្រាស់។

អត្ថបទនេះ, **ខ្មែរអាយធី** *សំរាប់អ្នក* សរសេរវា សំដៅណែនាំហូរហែរ វិធីប្រើប្រាស់ FormatFactory បំលែងរាល់អ្វី អ្នកចង់ និង វិធីបញ្ចូល កញ្ចប់អក្សរខ្មែរ ក្នុងវា សំរាប់ធ្វើផ្ទាំងប្រទាក់ របស់វា ជាអក្សរខ្មែរ ១០០ % សំរួលបំរើប្រាស់ របស់គ្រប់កូនខ្មែរ ទាំងក្នុងប្រទេស ទាំងឯនាយសមុទ្រ និងផងដែរ ទាំងខ្មែរនៅកម្ពុជាក្រោម ទាំងខ្មែរនៅខេត្តសុរិន្ទ ប្រទេសសៀម។

## ជំហាន ១ ៖ ទាញយក / តំលើង កម្មវិធី FormatFactory និង បញ្ចូល កញ្ចប់អក្សរខ្មែរ សំរាប់វា

1. ចុចទាញយក/តំលើង កម្មវិធី FormatFactory លើខំព្យូរើ
2. ចុចទាញយក កញ្ចប់អក្សរខ្មែរ សំរាប់វា ឬ ចុច 1 2
3. បន្ទាប់ការតំលើងរួចរាល់ FormatFactory ត្រូវតែអនុវត្ត ១...




ចំលង/បិទភ្ជាប់ កញ្ចប់អក្សរខ្មែរ នៅទីតាំង C:/Program Files/FreeTime/FormatFactory/Lang (១)




ចូរប្រតិបត្តិ ២...៤ សំរាប់ធ្វើផ្ទាំងប្រទាក់ របស់ FormatFactory ជា អក្សរខ្មែរ ១០០ %

# ជំហាន ២ ៖

## ណែនាំប្រើប្រាស់ FormatFactory សំរាប់ បំលែងតាមចង់ ទ្រង់ទ្រាយ របស់រូបភាព / អឌាវ / វីឌីអូ សំរាប់អ្នក

អ្នកអាចបំលែង រាល់ទ្រង់ទ្រាយ រូបភាព / អឌាវ / វីឌីអូ ត្រូវតាម ឧបករអាន (Reader) ឬ ឧបករលេង (Player) អ្នកចង់ប្រើប្រាស់។

ពពួករូបភាព ខាងក្រោម បានណែនាំប្រើប្រាស់ កម្មវិធី Format Factory សំរាប់បំលែង ទាន់ចិត្ត/តាមចង់ រូបភាព / អឌាវ / វីឌីអូ សំរាប់អ្នក។ អ្នកត្រូវតែអនុវត្ត ហ្វូរហែរ តាមលំដាប់លេខ លើ រូបភាពនីមួយ។



















FormatFactory ប្រាកដជាពោរពេញ អានុភាព ព្រោះវាបំលែង មួយឯកសារ វីឌីអូ ទំហំ ២៥,០៣ មេកាបៃ អស់ពេល ត្រឹម ១៥ វិនាទី។

អ្នកអាចប្រើប្រាស់វា បំលែងតាមចង់ ត្រឹមមួយប៉ព្រិចភ្នែក គ្រប់ឯកសារ រូបភាព / អឌាវ / វីឌីអូ សំរាប់ ទូរសព្ទ ចល័ត, ឧបករចល័ត, ឧបករថតរូប, ឧបករថតវីឌីអូ របស់អ្នក គ្មានចាំបាច់ អស់លុយ សូម្បីមួយសេន សំរាប់ពឹង អ្នកជំនាញ។

# ជំហាន ៣ ៖

## កំណត់ទំរង់ វិនដោស្ស ៧ សំរាប់ បង្ហាញចេញច្បាស់ រាល់អក្សរខ្មែរ លើ ផ្ទាំងប្រទាក់ (Interface) របស់ FormatFactory
















**ខ្មែរអាយធីសំរាប់អ្នក**

**ជា ពន្លឺចំណេះខំព្យូរើ សំរាប់កូនខ្មែរ !!!**

*អានផងដែរ៖*

- តំលើង/ប្រើប្រាស់ឥតគិតថ្លៃ ស្កេភី (Skype) ជាអក្សរខ្មែរ ១០០% សំរាប់ញៀឆ្លងទ្វីប..
- បង្កើត/គ្រប់គ្រងឥតគិតថ្លៃ បណ្តាញសង្គម (Social Network) ជាអក្សរខ្មែរ ១០០% ...

ពាក្យបានប្រើប្រាស់៖

- digital song : ចំរៀងលេខ, ចំរៀង មានលក្ខណៈជា សំណុំពត៌មាន (files) សំរាប់ប្រើប្រាស់ ជាមួយពួកសំភារៈលេខ (digital devices)
- analog data : ទិន្នន័យរលក (ជាទិន្នន័យ មានសញ្ញា ជារលក (រាង sinusoidal) )
- digital data : ទិន្នន័យលេខ (ជាទិន្នន័យ មានសញ្ញា ជារាង 1 និង 0 (រាង Pulse), វាជាទិន្នន័យ មានភាពជាក់លាក់ខ្ពស់ (high precision) សំរាប់ បន្ទេរទិន្នន័យ (data transmission) បើប្រៀបជាមួយ ទិន្នន័យរលក។ បច្ចុប្បន្ន ទិន្នន័យលេខ ត្រូវបានប្រើប្រាស់ ទូទៅ ក្នុងបច្ចេកវិទ្យាខ្ពស់ (high tech))




បានបន្ទាន់សម័យ ថ្ងៃ 30/10/2009



ក្ដារចុចពុម្ពអក្សរ ខ្មែរយូនីកូដ
Clavier Khmer Unicode
NiDA Standard
http://www.khmeros.info/drupal
Ctrl+Alt
Alt Gr
ក្ដារចុច AZERTY
khmeritforyou.blogspot.com
Back Space
Tab
Enter
Caps Lock
Shift
Ctrl
Alt
SPACE
Alt Gr
30/10/2009